# រឿងនាងចិញ្ចា

## នារីអភ័ព្វសម័យពុទ្ធកាល

ការច្រណែនឈ្នានីសនិងការប្រកួតប្រជែង បៀតបៀន មួលបង្កាច់ របស់ជនចិត្តអបលក្ខណ៍ទាំងឡាយមិនមែនកើតមានឡើងតែក្នុងសម័យបច្ចុប្បន្ននេះទេ នៅក្នុងសម័យពុទ្ធកាលក៏មានរឿងបែបនេះកើតឡើងដែរ ហើយកើតឡើងចំពោះព្រះដ៏មានព្រះភាគដោយផ្ទាល់តែម្តង ។ សាច់រឿងដ៏គួរអោយរន្ធត់នេះ គឺព្រះអានន្ទជាអ្នកតំណាលប្រាប់ភិក្ខុផងគ្នា ដែលមានសេចក្តីតំណាលដូចតទៅនេះ :

កាលព្រះពុទ្ធសាសនាចំរុងរីនរុងរឿងថែងចាំងរង្សី បីដូចព្រះសូរិយាជះពន្លឺបណ្តេញរស្មីនៃអំពិលអំពែកគឺលទ្ធិពាហិរសាសនាផ្សេងៗអោយអាប់អោននោះ ពួកអន្យតិរ្ថិយនិគ្រន្ថទាំងឡាយក៏សាបសូន្យចាកលាភសក្ការៈ និង ការគោរពរាប់អានយ៉ាងខ្លាំងដោយមិនធ្លាប់កើតមានពីមុនមក ។

អ្នកបួសទាំងនោះក៏ត្រាច់ចរប្រកាសតាមផ្លូវបែកជាបី ផ្លូវបែកជាបួន នឹងតាមថ្នល់ដែលជាទីត្រាច់ចរនៃជនទាំងឡាយផ្សេងៗ ថា "អស់លោកអ្នកមានកែវភ្នែកទាំងឡាយ ព្រះសមណគោតមជាព្រះពុទ្ធយ៉ាងណា យើងទាំងឡាយក៏ជាព្រះពុទ្ធដូចគ្នា ធ្វើបុណ្យអោយទានដល់ព្រះសមណគោតមមានផលច្រើនយ៉ាងណា អោយដល់ពួកយើងក៏មានផលច្រើនយ៉ាងនោះ អស់លោកទាំងឡាយចូរអោយពួកយើងចុះ"។ កាលដែលអ្នកបួសទាំងអស់នោះត្រាច់ចរប្រកាសយ៉ាងនេះហើយ ក៏មិនអាចនឹងទាក់ទាញមនុស្សអោយជ្រះថ្លាតាមសេចក្តីត្រូវការបាន មិនតែប៉ុណ្ណោះ អ្នកដែលធ្លាប់ជ្រះថ្លាមានបញ្ញាល្មមពិចារណាបានក៏ឈប់ជ្រះថ្លា អ្នកដែលមិនជ្រះថ្លាស្រាប់ហើយ ក៏បែរជាស្អប់ខ្ពើមតែម្តង បានសេចក្តីថាវិធីរបស់ពួកអន្យតិរ្ថិយនេះមិនបានផលឡើយ ។

ពួកគេប្រជុំប្រឹក្សាគ្នាថា នឹងធ្វើយ៉ាងណាតទៅទៀត? ខណៈនោះមានអ្នកបួសគំនិតឆ្លាតវាងវៃម្នាក់ពោលឡើងថា "សំលាញ់ទាំងឡាយ ឧបាយនោះមានច្រើនប្រការណាស់ បើមិនបានដោយវិធីមួយក៏គួរប្រើវិធីដទៃតទៅទៀត កើតជាមនុស្សមិនគួរទាល់តម្រិះទេ ជារឿងធម្មតាបើទ្វារមួយបិទអាចមានទ្វារដទៃទៀត ក៏គួរសាកល្បងច្រានលមើលសិនទៅ ខ្ញុំនឹកឃើញដល់សិស្សម្នាក់របស់ពួកយើងនាងជាស្រីមានរូបឆោមលោមពណ៌ស្រស់ត្រកាលបីដូចទេពអប្សរ បើបានអាស្រ័យនាងជាជំនួយដល់ពួក

យើង ផែនការរបស់ពួកយើងអាចនឹងសំរេចបាន ឬមួយអស់លោកទាំងឡាយមានយោបល់យ៉ាងណា?"

និយាយចប់អ្នកបួសគ្រប់គ្នាក៏យល់ស្របទាំងអស់ ចំពេលដែលគេកំពុងប្រជុំគ្នាដោយសំងាត់នោះ នាងចិញ្ចមាណវិកាក៏ចូលមកសួរសុខទុក្ខតាមប្រក្រតីដូចដែលធ្លាប់ធ្វើមក អ្នកបួសទាំងអស់នោះធ្វើជាមិនចាប់អារម្មណ៍នឹងនាង ហើយក៏មិនបានសំណេះសំណាលរាក់ទាក់អ្វីទាំងអស់ នាងមានអារម្មណ៍ចំលែកក្នុងចិត្តជាខ្លាំង ទើបពោលឡើងថា " លោកម្ចាស់ កាលខ្ញុំមកលេងពីលើកមុន លោកម្ចាស់ធ្លាប់សំដែងអាការៈរីករាយស្វាគមន៍រាក់ទាក់យ៉ាងកក់ក្តៅ តែពេលនេះហេតុអ្វីក៏លោកម្ចាស់ធ្វើព្រងើយកន្តើយដូចជាខ្ញុំជាមនុស្សចំលែកគួរអោយស្អប់ខ្ពើម? សូមលោកម្ចាស់ប្រាប់នូវកំហុសឆ្គងរបស់ខ្ញុំអោយបានដឹងផង បើខ្ញុំដឹងកំហុសរបស់ខ្លួនហើយខ្ញុំនឹងបានកែប្រែឡើងវិញ" ។

"ប្អូនស្រី នាងរវល់ទៅសប្បាយភ្លើតភ្លើនឯណា ទើបមិនដឹងពីសេចក្តីទុក្ខរបស់ពួកយើង ពួកយើងត្រូវព្រះសមណគោតមកំពុងបៀតបៀន ធ្វើអោយអាប់អោនទាំងលាភសក្ការៈនិង កិត្តិគុណ នាងមិនឈឺឆ្អាលជំនួសពួកយើងខ្លះទេឬអី?"

"បពិត្រលោកម្ចាស់ បុរាណលោកបានពោលថា មិត្តភក្តិស្គាល់គ្នាក្នុងគ្រាក្រ ពេលនេះលោកម្ចាស់ទាំងឡាយកំពុងជួបប្រទះនូវរឿងក្តៅក្រហាយ ខ្ញុំទាំងជាមិត្តនិងជាបរិវារ អោយនៅព្រងើយម្តេចនឹងកើត ចូរប្រាប់មកចុះ ខ្ញុំរីករាយនឹងប្រតិបត្តិតាមដើម្បីសេចក្តីសុខនិងភាពរុងរឿង របស់លោកម្ចាស់ " ។

អន្សុត្តិរិយទាំងអស់នោះពេញចិត្តនឹងសំដីរបស់នាងបរិពាជិកាយ៉ាងខ្លាំង ពេលនោះមានអ្នកបួសម្នាក់ពោលឡើងថា " ម្នាលប្អូនស្រី ពួកយើងនឹងមិនភ្លេចអំពើល្អរបស់ប្អូនស្រីក្នុងពេលនេះទេ បើកិច្ចការធំលើកនេះបានសំរេច នាងនឹងមានគុណបំណាច់ដ៏ឧត្តុង្គឧត្តម ម្យ៉ាងទៀត នាងប្រាប់ថានាងជាស្រីនិងជួយពួកយើងម្តេចនឹងបាន ប្អូនស្រី! ក៏នាងដឹងហើយមិនមែនទេឬថា អ្វីទៅជាសេចក្តីវិនាសយ៉ាងខ្លាំងសំរាប់អ្នកបួស ជាងការទៅច្រឡូកច្របល់បូកឡុកជាមួយស្ត្រីភេទ ប្រៀបដូចជាដង្កូវដែលបង្កភាពអន្តរាយបំផុតចំពោះសាច់ ។ ចិញ្ចមាណវិកាអើយ នាងចូរអាស្រ័យភាពជាស្ត្រីរបស់នាងហ្នឹងហើយបំផ្លាញកិត្តិយសដ៏រុងរឿងខ្ពង់ខ្ពស់របស់ព្រះសមណគោតមអោយវិនាសហិនហោច" ។

នាងចិញ្ចមាណវិកាពោលឡើងថា "បពិត្រលោកម្ចាស់ បើអញ្ចឹង ទុកនាទីនេះអោយខ្ញុំចុះ គង់នឹងអាចសំរេចសមបំណងបានជាមិនខាន" និយាយហើយនាងក៏លាត្រឡប់ទៅកាន់គេហដ្ឋានវិញ ។

ពីរបីថ្ងៃក្រោយមក អ្នកនគរសាវត្ថីដែលជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ ហើយទៅស្តាប់ធម្មទេសនារាល់ៗល្ងាច ពេលត្រឡប់ចេញពីវត្តជេតពនវិញ តែងតែឃើញនាងចិញ្ចមាណវិកាបរិពាជិកាដើរចូលទៅក្នុងអារាម ពេលមានអ្នកសួរនាងថា "នាងទៅណា?" ក៏ឆ្លើយត្រឹមតែពាក្យថា "មិនមែនជារឿងដែលពួកអ្នកឯងត្រូវដឹងនោះទេ" រួចហើយក៏ដើរចូលទៅក្នុងវត្តជេតពនបាត់ទៅ ។

លុះព្រឹកឡើងពេលដែលមហាជនចូលមកកាន់វត្តជេតពនដើម្បីថ្វាយយាគូ (បបរ) និងភត្តាហារដល់ព្រះដ៏មានព្រះភាគនិងព្រះសង្ឃ នាងតែងតែដើរចេញពីវត្តទៀត ពេលគេសួរថា "នាងមកពីណា?" នាងតែងតែឆ្លើយដូចមុនថា "មិនមែនជារឿងដែលអ្នកឯងត្រូវដឹងទេ ថាយើងមកពីណាហើយដេកឯណា" ។

នាងធ្វើយ៉ាងនេះអស់រយៈពេលប្រហែល២ខែ ហើយធ្វើយ៉ាងជាប់លាប់ជានិច្ចកាលរៀងរាល់ថ្ងៃ ថ្ងៃបន្តបន្ទាប់មកទៀតនាងធ្វើហាក់ដូចជាអត់ធន់តទៅទៀតមិនបាន ពេលមាននរណាម្នាក់ក្នុងចំណោមមហាជនទាំងឡាយសាកសួរឡើងទៀតនាងក៏ពោលថាៈ

"អស់លោកទាំងឡាយទៅគាល់ព្រះសាស្តាទាំងព្រឹកល្ងាច គោរពបូជាព្រះអង្គយ៉ាងខ្ពង់ខ្ពស់ សូម្បីព្រះរាជាក្នុងដែនកោសលដែលបរិបូរណ៍ទៅដោយអំណាចយសសក្តិ ក៏លើកតំកើងព្រះអង្គរកអ្វីប្រៀបប្រដូចគ្មាន តែអស់លោកទាំងឡាយ ព្រមទាំងព្រះរាជាមិនបានដឹងទាល់តែសោះថា មនុស្សដែលជាកំណាន់ចិត្តរបស់ព្រះសមណគោតមនោះគឺនរណា" នាងនិយាយបន្សល់ទុកត្រឹមនេះហើយក៏ញញឹមចំអក ។ ប្រជាជនក៏សួរដេញដោលតទៅទៀតថា " ចុះនរណាទៅជាទីស្រលាញ់ពេញព្រះទ័យរបស់ព្រះដ៏មានព្រះភាគអង្គនោះ នាងដឹងទេ?" នាងចិញ្ចមាណវិកាក៏ឆ្លើយតបថា "ថីមិនដឹង! ព្រះសមណគោតមរីករាយសប្បាយជាមួយនរណាជារៀងរាល់យប់ អ្នកនោះឯងជាទីស្រលាញ់ពេញចិត្តរបស់ព្រះអង្គ អ្នកអើយ! ធម្មតាបុរសដែលទំនេរចាកស្ត្រីភេទសំរាប់ប្រលែងប្រលោមនោះ នឹងទ្រាំម្តេចបាន ឧបមាដូចជាគោទំនេរចាកស្មៅខ្ចីឬក្របីទំនេរចាកថ្លុក មនុស្សដែលស្រលាញ់គ្នារមែងមិនទំនេរចាកការប្រលោមនៃបនិត្យ ឬដូចជាស្តេចហង្សរមែងអភិរម្យរីករាយចំពោះស្រះបោក្ខរណី តាបសឥសីរមែងមិនទំនេរចាកការចូលឈាន ។ ហៃអ្នកដ៏ងងឹតងងល់ទាំងឡាយ! ក៏ព្រះសមណគោតមនោះចាកចេញពីព្រះរាជវាំងដ៏ល្អវិចិត្រខ្ពស់ស្កឹមស្កៃ ហែហមទៅដោយស្ត្រីដែលចាំតែបំរុងបំរើ ផ្គាប់ផ្គុនដោយកាមរស

ហើយឥឡូវនេះ ព្រះអង្គបានទំនេរចាករបស់ទាំងអស់នោះអស់រយៈពេលជាយូរមកហើយ ពេលដែលបានជួបស្ត្រីដែលមានរូបសម្ផស្សស្រស់ត្រកាលគាប់ភ្នែក និងមានវង់ភក្ត្រផូរផង់ដូច្នេះ តើអោយព្រះអង្គទ្រាំម្តេចនឹងបាន ព្រះអង្គតែងតែឆក់ឱកាសប្រលោមប្រលែងនៃបនិត្យអោយសមនឹងចិត្តដែលទំនេរមកយូរយារដូច្នោះដែរ ដូចមច្ឆាជាតិដែលអន្ទះអន្ទែងព្រោះខ្វះទឹកក្នុងរដូវប្រាំង ពេលបានឮសំលេងផ្គរមកពីទិសខាងលិចក៏រមែងឆ្លេឆ្លា ហើយពេលដែលព្រះភិរុណបង្អុរភ្លៀងចុះមកយ៉ាងធំតាំងពីព្រលឹមទល់ព្រលប់ធ្វើអោយទឹកហូរហៀរពេញត្រពាំងបឹងបួរ មច្ឆាជាតិទាំងនោះនឹងមានសេចក្តីរំភើបរីករាយលោតកញ្ជ្រោលសប្បាយប៉ុណ្ណា នែ! អ្នកដ៏ងងឹតងងល់! សេចក្តីនេះយ៉ាងណា ព្រះមហាសមណគោតមក៏យ៉ាងនោះដែរ" ។ ប្រជាជននៅសួរដេញដោលតទៅទៀតថា

"ចុះនាងឬជាទីស្រលាញ់ពេញចិត្តយ៉ាងខ្លាំងរបស់ព្រះមហាសមណគោតម?"

"ខ្ញុំបានប្រាប់ហើយតើ! ថាព្រះសមណគោតមប្រលោមប្រលែងជាមួយនរណារាល់យប់ អ្នកនោះរមែងជាទីស្រលាញ់យ៉ាងខ្លាំងរបស់ព្រះអង្គ ក៏ខ្ញុំហ្នឹងហើយជាអ្នកដែលព្រះអង្គទ្រង់បញ្ជាអោយគេរកមករួមសុខជាមួយ កុំអោយខ្ញុំត្រូវប្រាប់ទៀតអី អ្នកគប្បីពិចារណាដោយខ្លួនឯងចុះថា រឿងនោះវាគួរតែទៅជាយ៉ាងណា?" និយាយហើយនាងក៏ដើរហួសទៅ ដើម្បីអោយពាក្យសំដីដែលប្រៀបប្រដូចទៅនឹងថ្នាំពិសនោះបញ្ចេញឫទ្ធិរបស់វាដោយស្វ័យប្រវត្តិ ដោយមិនរងចាំពាក្យដេញដោលរបស់ប្រជាជនទៀត ។

ហើយអ្វីៗក៏កើតឡើងជាយថាហេតុ សម្តីរបស់នាងបង្កនូវភាពសង្ស័យអោយកើតឡើងក្នុងចិត្តរបស់ពុទ្ធបរិស័ទដោយមិនអាចហាមឃាត់បាន ប្រកបជាមួយនឹងរឿងដែលឃើញប្រចក្សទូទៅគ្រប់គ្នាដ៏គួរឱ្យជឿគឺកាលពី២ខែមុននេះនាងបានដើរចេញចូលក្នុងវត្តជេតពនទាំងព្រឹកល្ងាច ។ ពួកនិគ្រន្ថអន្យតិរ្ថិយទាំងឡាយបានឱកាសដូច្នោះហើយ ក៏ជួយគ្នាផ្សព្វផ្សាយដំណឹងអោយសាយរាលដាលដូចជាភ្លើងដែលមានឧសល្អហើយបានទទួលកំលាំងខ្យល់ ។

ប៉ុន្តែហេតុការណ៍ក្នុងវត្តជេតពននៅតែរក្សានូវភាពស្ងប់ស្ងៀមនៅឡើយ ភិក្ខុទាំងឡាយនៅតែបំពេញសមណធម៌និងស្វាធ្យាយព្រះពុទ្ធវចនៈតាមប្រក្រតី មានម្តងម្កាលដែលភិក្ខុអង្គខ្លះសំដែងចេតនាចង់រម្ងាប់នូវដំណឹងនេះ តែព្រះពុទ្ធអង្គទ្រង់ហាម សាវ័កអ្នកជឿក្នុងអនាគតង្សញ្ញាណនៃសាស្តារបស់ខ្លួនទើបនៅតែស្តាប់ពាក្យចចាមអារាមនេះដោយចិត្តស្ងប់ ។

ម្នាលអាវុសោ! ខ្ញុំក៏មានចិត្តក្តៅក្រហាយខ្វល់ខ្វាយចំពោះរឿងនេះមិនតិចដែរ តែក៏រំងាប់ទៅវិញបានដោយព្រះពុទ្ធពេចន៍ដែលត្រាស់លួងលោមថា *" អានន្ទ! កុំកើតក្តីក្តៅក្រហាយឡើយ អ្នកដែលចាប់លាមកគប់ទៅកាន់ដួងព្រះច័ន្ទរមែងជួបសេចក្តីក្តៅក្រហាយចំពោះខ្លួនឯងដោយហេតុពីរយ៉ាងគឺៈ ដៃរបស់គេរមែងកខ្វក់ដោយប្រឡាក់ជាប់ក្លិនស្អុយ ប្រការមួយ ហើយប្រការមួយទៀត គេនឹងទោមនស្សកាន់តែខ្លាំងឡើងពេលដែលលាមកដែលគេគប់ឡើងទៅនោះ មិនអាចធ្វើអោយមណ្ឌលព្រះច័ន្ទប្រឡាក់សៅហ្មងបាន តែត្រឡប់ជាធ្លាក់ចុះមកធ្វើអោយក្បាលនិងអវៈយវៈរបស់អ្នកគប់កខ្វក់ប្រឡាក់ប្រឡូសដោយខ្លួនឯង ខនេះយ៉ាងណា អ្នកណាព្យាយាមមួលបង្កាច់តថាគតក៏យ៉ាងនោះដែរ"* ។ ម្នាលអាវុសោ! ក្នុងករណីនេះ ព្រះបរមសាស្តាប្រៀបដូចជាមេបញ្ជាការប៉ូលិសដ៏ឆ្លាតក្នុងការចាប់ជនទុច្ចរិត ពេលដែលឃើញនិងដឹងតម្រុយថា ចោរបំរុងចូលប្លន់ផ្ទះក៏មិនចាប់ក្នុងពេលភ្លាមៗនោះទេ ប្រមាណកំលាំងរបស់ចោរហើយក៏ត្រៀមកំលាំងប៉ូលិសទុក ចាប់អោយបានទាំងភស្តុតាង ដើម្បីមិនអោយចោរមានផ្លូវរើបំរះឬដោះស្រាយបានដោយប្រការណាមួយ ។

រយៈពេលមួយខែក្រោយមកទៀត នាងចិញ្ចមាណវិកា ក៏បានយកក្រណាត់ចាស់ៗបត់ជាច្រើនជាន់ដាក់ត្រង់ពោះ ហើយក៏បន្ថែមឡើងបន្តិចម្តងៗ សំដែងអាការៈដូចជាមានផ្ទៃពោះកាន់តែចាស់ខែឡើងជាលំដាប់ លុះឈានចូលដល់ខែទី៨ ទី៩ នាងយកដំបងវាយតាមខ្នងដៃខ្នងជើងអោយហើមដើម្បីអោយសមនឹងអាការៈរបស់អ្នកមានគភ៌ចាស់ខែជិតដល់ពេលសំរាល ។ រឿងនេះចលាចលយ៉ាងខ្លាំងក្នុងក្រុងសាវត្ថី ក្នុងឆ្នាំនោះលើកលែងតែព្រះអរិយសាវ័កចេញ មហាជនក្រៅពីនេះជឿជាក់ថានាងមានគភ៌ជាមួយព្រះសាស្តា តែព្រះពុទ្ធអង្គក៏ទ្រង់នៅស្ងៀមព្រងើយដដែល ចៃដន្យព្រះអរិយសាវ័កគង់នៅច្រើនអង្គ ទើបធ្វើអោយពុទ្ធបរិស័ទក្នុងវត្តជេតពននៅតែកុះករ ។

គ្រប់ទីកន្លែងមានការសួរដេញដោលគ្នាជាកោលាហលពីរឿងនេះ តាមផ្លូវបែកជា៣ផ្លូវបែកជា៤ ក្នុងទីសាធារណៈ និងទីប្រជុំនានា មានការប្រកែកគ្នា និងបញ្ចេញមតិដ៏ទូលំទូលាយថា ជារឿងដែលអាចកើតឡើងបានឬមិនបាន ។ មនុស្សទាំងឡាយចែកចេញជាពីរពួក ពួកដែលជឿថាអាចកើតឡើងបានមែនក៏អស់សទ្ធាចំពោះព្រះសាស្តា ពួកដែលមិនជឿក៏ជួយគ្នាដោះស្រាយជំនួសព្រះអង្គ ។

ថ្ងៃមួយខ្ញុំមានអារម្មណ៍តប់ប្រមល់ខ្វល់ខ្វាយព្រោះរឿងនេះសារជាថ្មីម្តងទៀត ប្រសិនបើក្រាបទូលព្រះសាស្តា ព្រះអង្គក៏នៅតែព្រងើយដដែល ទើបខ្ញុំដើរចេញពីវត្តជេតវនារាមឆ្ពោះទៅកាន់ទិសទក្សិណ ក្នុងទីនោះជាព្រៃឈើដុះចោលម្លប់ត្រជាក់ល្ហឹម ។

ខ្ញុំត្រូវការនៅក្នុងទីស្ងប់ស្ងាត់ដើម្បីរម្ងាប់ចិត្តដែលពុះកញ្ជ្រោលដោយសារតែការព្រួយបារម្ភចំពោះព្រះសាស្តាជាទីគោរពយ៉ាងខ្ពង់ខ្ពស់របស់ខ្ញុំ ខ្ញុំជឿថាព្រះសាស្តាមិនបានធ្វើនូវកម្មដ៏គំរក់នោះទេ តែនឹងហាមមាត់មនុស្សមិនអោយនិយាយម្តេចនឹងបាន ក្នុងឋានៈខ្ញុំជាអ្នកជំនិតបំផុតរបស់ព្រះអង្គ ហើយជួនកាលពេលដែលខ្ញុំចេញបិណ្ឌបាតក្នុងពេលព្រឹក មានព្រាហ្មណ៍កំលោះនិងអ្នកបួសសាសនាដទៃ និយាយចំអកឡកឡឺយបញ្ចិតបញ្ចៀងឱដងអោយឈឺចាប់និងអាម៉ាស់ តែខ្ញុំក៏ខំព្យាយាមអត់សង្កត់ចិត្តមិនសំដែងអាការៈក្រោធខឹងតាមព្រះតម្រាស់របស់បរមព្រះសាស្តា ។

*"ហៃសាធុជនទាំងឡាយអើយ មនុស្សភាគច្រើនក្នុងលោកនេះ ពេញចិត្តតែនឹងរឿងវិបត្តិលិចលង់ រឿងអាម៉ាស់អាស្រូវរបស់អ្នកដទៃ ចាត់ទុកជាអាហារសំដីដ៏មានឱជារសដើម្បីនឹងបានទំពារលេងតាមកន្លែងជួបជុំក្នុងពេលទំនេរ ទោះជាគេមិនត្រូវការសភាពដូច្នោះ បើកើតឡើងចំពោះខ្លួនគេក៏ដោយ"* ។

ក្នុងខណៈដែលខ្ញុំកំពុងតែរំពឹងគិត មានក្មេងកំលោះត្រកូលព្រាហ្មណ៍ពីរនាក់ដើរចូលមកដោយមិនបានឃើញខ្ញុំ ហើយគេក៏អង្គុយសំរាកនៅក្រោមដើមឈើមួយដើមទៀត ដោយបែរខ្នងដាក់ខ្ញុំ ។

"វ៉ាសេដ្ឋៈ" ក្មេងកំលោះម្នាក់និយាយឡើង "អាកាសស្អុះស្អាប់មែនទែន មកសំរាកក្នុងព្រៃនេះគ្រាន់បានត្រជាក់បន្តិច បើវត្តិយាបានមកជាមួយផងប្រហែលជាអាចរីករាយឡើងទ្វេដងថែមទៀត" ឈ្មោះនោះគេប្រហែលជានិយាយសំដៅដល់គូស្នេហ៍របស់គេ ។

"មនុស្សដែលមានគូស្នេហ៍ថ្មីៗក៏តែប៉ុណ្ណឹង!" ក្មេងកំលោះម្នាក់និយាយឡើង "ឃើញអ្វី ទៅទីណាក៏នឹកដល់តែគូស្នេហ៍ ដកដង្ហើមចេញចូលក៏នឹកឃើញតែគូស្នេហ៍រហូត" ។

"ខ្ញុំនៅកំលោះពេញកំលាំង ហើយមានគូស្នេហ៍គួរអោយស្រលាញ់ដូចវត្តិយា នឹងមិនអោយខ្ញុំស្រមើស្រមៃរវើរវាយម្តេចកើត កុំថាឡើយដូចជាពួកយើង សូម្បីតែព្រះសមណគោតមបរមសាស្តាក៏នៅមាននាងចិញ្ចាទុកគ្រាន់ប្រលោមប្រលែងដែរ ។ អើ! តាមពិតមិនគួរនឹងកើតឡើងសោះ ភារទ្វាជៈ! តែរឿងវ៉ាវ វាក៏កើតឡើងទៅហើយ" ។

ខ្ញុំភ្ញាក់កន្ត្រាក់អស់ទាំងខ្លួន អនិច្ចា! មិនថាគេចវេះទៅនៅកន្លែងណា ទីណា ខ្ញុំតែងតែបានឮនូវសំដីដែលមិនជាទីគាប់ចិត្តនេះទាំងអស់។ ដែនកោសលមហារដ្ឋនិងដែនជិតខាងពេលនោះហុយទ្រលោមទៅដោយផ្សែងភ្លើង គឺពាក្យចចាមអារាមពីរឿងព្រះសាស្តានិងនាងចិញ្ចា ខ្ញុំតឹងទ្រូងឥតឧបមា ចង់ស្ទុះក្រោកឡើងទៅបកស្រាយអោយក្មេងទាំងពីរនាក់នោះយល់អោយបានត្រឹមត្រូវថា កម្មដ៏គួរឱ្យអាម៉ាស់នោះ ព្រះសាស្តាមិនបានធ្វើទេ ស្រាប់តែបានឮសំលេងក្មេងកំលោះម្នាក់ទៀតនិយាយឡើងថា:

"វ៉ាសេដ្ឋះ! ជឿដែរទេថាព្រះសមណគោតមទ្រង់ធ្វើដូច្នោះមែន?"

"សាក្សីនិងភស្តុតាងច្បាស់ក្រឡែតប៉ុណ្ណឹងហើយ ឯងនៅតែមិនជឿទៀតឬភារទ្វាជះ?ខាងស្រីគេជាអ្នកខូចឈ្មោះ បាត់បង់កិត្តិយស ហើយនិយាយចេញមកកកោកថា ឪពុករបស់ក្មេងក្នុងផ្ទៃគឺនរណា ហេតុការណ៍ដែលកើតឡើងអស់រយៈពេលប្រាំមួយប្រាំពីរខែកន្លងមកនេះ ក៏ល្មមយកមកធ្វើជាគ្រឿងបញ្ជាក់បាន នាងចិញ្ចមាណវិកាដើរចេញចូលក្នុងវត្តជេតពនមិនប៉ុន្មានក៏មានផ្ទៃពោះ នរណាក៏គេឃើញ"

"តែខ្ញុំមិនទាន់ជឿ រឿងយ៉ាងនេះជារឿងដែលអាចមួលបង្កាច់គ្នាបាន *មនុស្សស្រីជាឧបករណ៍ដ៏សំខាន់បំផុតក្នុងការប្រើប្រាស់ធ្វើជាគ្រឿងបំផ្លាញកិត្តិយសរបស់នរណាម្នាក់*"

"សំលាញ់ភារទ្វាជះ រឿងនេះបើគ្មានភស្តុតាងទេ គ្នាក៏មិនជឿដែរ តែពេលនេះពោះរបស់នាងចិញ្ចាជាសាក្សីសំខាន់ដែលមិនអាចអោយនរណាប្រកែកកបានថា ព្រះសមណគោតមមិនបានប្រកបកម្មដ៏គួរអោយអាម៉ាស់នោះ" ។

"តែខ្ញុំនៅតែមិនជឿ" ភារទ្វាជះនិយាយយ៉ាងច្បាស់លាស់ "ទំរាំដល់ថ្ងៃដែលនាងចិញ្ចមាណវិកាសំរាលសាក្សីសំខាន់នោះចេញមកមែនៗ គឺទារកដែលសំរាលចេញមកនោះជាសាក្សី មិនមែននាងចិញ្ចានោះទេហើយសូម្បីតែទារកដែលសំរាលចេញមកហើយ បើមិនមានទម្រង់មុខនៃព្រះតថាគតជាម្ចាស់ទេ ខ្ញុំក៏មិនទាន់ជឿជាក់ដែរ"។ ខ្ញុំធ្លាប់ឃើញនាងបរិពាជិកាម្នាក់នេះ ដើរចុះឡើងនៅតាមវត្តរបស់ពួកនិគ្រន្ថអន្យតិរ្ថិយជាញឹកញាប់ នាងអាចមានផ្ទៃពោះជាមួយនរណាម្នាក់ក៏បានក្នុងចំណោមពួកនិគ្រន្ថអន្យតិរ្ថិយទាំងអស់នោះ ហើយពួកនោះក៏ជាសត្រូវរបស់ព្រះសម្មាសម្ពុទ្ធស្រាប់ផងទាំងដែលព្រះអង្គមិនធ្លាប់ជាសត្រូវជាមួយនរណាសោះ ឯងធ្លាប់បានឮដែរតើ! ពួកនោះដើរប្រកាសក្តែងៗ ដើម្បីអោយមហាជនជ្រះថ្លាចំពោះខ្លួនតែក៏មិនបានសំរេច លុះពួកនោះឈប់ប្រកាសមិនបានប៉ុន្មានផងរឿងរបស់នាង

ចិញ្ចាក៏ផុសឡើងមកទៀត សំលាញ់! កុំជឿអ្វីងាយៗពេក យើងនាំគ្នាចាំមើលអោយដល់ទីបំផុតសិន មនុស្សក្នុងលោកនេះចូលចិត្តមួលបង្កាច់គ្នា ជាពិសេសមនុស្សដែលមានផលប្រយោជន៍មិនស្របគ្នា" ។

"ខ្ញុំមិនមែនជាមនុស្សឆាប់ជឿដោយងាយៗទេ ឯងក៏ដឹង ខ្ញុំប្រាកដក្នុងចិត្តថា មនុស្សឆាប់ជឿជាមនុស្សងប់គ្មានហេតុផល តែចំពោះមនុស្សដែលមិនព្រមជឿអ្វីសោះ ក៏ជាមនុស្សគ្មានហេតុផលដូចគ្នា ហើយមើលទៅដូចជាគ្មានហេតុផលជាងអ្នកដែលឆាប់ជឿទៅទៀត"

"ខ្ញុំមានថាអី! " ភារទ្វាជៈនិយាយកាត់ "ខ្ញុំគ្រាន់តែប្រាប់ថា អោយចាំមើលរហូតដល់ទីបំផុត"

និយាយហើយ ក្មេងទាំងពីរក៏នាំគ្នាដើរចេញពីព្រៃនោះទៅ ទុកអោយខ្ញុំស្ថិតនៅក្នុងភាពច្របូកច្របល់វិលវល់ហួសបរិយាយ ។

មិនយូរប៉ុន្មាន ថ្ងៃដ៏សែនរន្ធត់ក៏មកដល់ វាប្រៀបដូចជាថ្ងៃកាត់ក្តី សំរេចអោយគង់នៅឬរលត់សូន្យសុងទៅនៃព្រះពុទ្ធសាសនា បើរឿងរបស់នាងចិញ្ចមាណវិកាជារឿងពិតក៏ជាការរលាយរលត់ទៅនៃព្រះពុទ្ធសាសនា ប្រសិនបើរឿងរបស់នាងចិញ្ចមាណវិការជារឿងមិនពិតក៏បានជានិមិត្តថា ព្រះពុទ្ធសាសនានឹងរុងរោចន៏តទៅ ។ ទង្វើទាំងនេះប្រៀបដូចជាមនុស្សល្ងង់ខ្លៅយកអាចម៍ប្រចៀវទៅបាចដាក់ដើមស្រូវដោយមានចេតនាអោយស្រូវងាប់ ប៉ុន្តែអាចម៍ប្រចៀវជាជីយ៉ាងល្អសំរាប់ស្រូវ បែរជាធ្វើអោយស្រូវរឹតតែលូតលាស់ខៀវខ្ចីកាន់តែខ្លាំងឡើង ។

ថ្ងៃនោះ ព្រះសម្មាសម្ពុទ្ធទ្រង់គង់ប្រថាប់សំដែងព្រះធម៌ទេសនានៅក្នុងសាលាធម្មសភា ព្រះអង្គទ្រង់មានសិរីចែងចាំងត្រចះត្រចង់បីដូចដួងច័ន្ទ្រកណ្តាលនភាល័យដែលប្រាសចាកពពក ។ ខណៈដែលពុទ្ធបរិស័ទកំពុងតែបង្អោនចិត្តទៅតាមក្រសែនៃព្រះធម៌ទេសនានោះឯង នាងចិញ្ចមាណវិកាក៏បង្ហាញខ្លួនឡើងកណ្តាលចំណោមពុទ្ធបរិស័ទ នាងឈរច្រត់ចង្កេះដោយដៃម្ខាង ចំណែកដៃម្ខាងទៀតចង្អុលព្រះភក្ត្រព្រះតថាគតដោយអាការៈក្អេងក្អាង "សំដែងធម៌បានពីរោះណាស់ ព្រះគោតម! សំលេងរបស់លោកពីរោះគឹកកងលន្លោចចាប់ចិត្តមហាជន ធ្មេញរបស់លោករាបស្មើ វាចាដែលបន្លឺចេញមកសុទ្ធតែអោយមនុស្សទាំងឡាយលះបង់នូវលោកិយវិស័យ តែចំពោះព្រះសមណគោតមខ្លួនឯងនោះ លះបង់បានដែរឬទេ? កិរិយាសំដែងធម៌ពូកែធ្វើបានផ្អែមល្ហែមពីរោះ មិនចាញ់បទលោមនាងក្នុងបន្ទប់ដេកសោះឡើយ"

ព្រះតថាគតជាម្ចាស់ទ្រង់ឈប់សំដែងធម៌ ពុទ្ធបរិស័ទទាំងឡាយស្ថិតក្នុងសភាពស្ងប់ស្ងាត់ជ្រងំ

បរិយាកាសជុំវិញទីនោះសែនស្ងប់ស្ងាត់គួរអោយស្រងេះស្រងោចហួសបរិយាយ ដើមឈើគ្រប់ដើមក្នុងវត្តជេតពនឈរស្ងៀមទ្រឹងហាក់ដូចជាគ្មានជីវិត ។

"ពូកែតែខាងប្រលោមសប្បាយ" នាងចញ្ចមាណវិកាជះវាចាដ៏គំរោះគំរើយតទៅទៀត "ព្រះគោតម! បែរមកមើលខ្ញុំអោយបានច្បាស់មើល៍ ឥឡូវនេះពោះរបស់ខ្ញុំជាង៩ខែហើយ តាំងពីមានផ្ទៃមកនឹងព្រួយបារម្ភខ្វល់ខ្វាយសូម្បីបន្តិចក៏គ្មាន កាលនៅថ្មីៗ ពេលផ្ដើមប្រលោមសប្បាយ ពូកែខាងរកពាក្យពេចន៍ផ្អែមល្ហែមពីរោះមកលួងលោមអោយស្រីស្លាប់ចិត្តណាស់ លុះមានផ្ទៃពោះចាស់ខែហើយនឹងចាត់ចែងរកគ្រូពេទ្យរកថ្នាំមករក្សាថែទាំកូនសូម្បីបន្តិចក៏គ្មាន ។ បើមិនធ្វើដោយខ្លួនឯង ក៏គួរប្រគល់ភារៈអោយសិស្សានុសិស្សទាំងឡាយដែលមានសទ្ធា ដូចជានាងវិសាខា ឬអនាថបិណ្ឌិកៈ ឬក៏ព្រះបាទបសេនទិកោសល អោយជួយចាត់ចែងទីកន្លែងសំរាប់សំរាល និងរក្សារសុវត្ថិភាពផ្សេងៗផងដែរ មិនមែនគ្រាន់ តែសំរាប់មនុស្សដែលខ្លួនឯងពោលថាស្រលាញ់ប៉ុណ្ណោះទេ តែសំរាប់ទារកដែលជាសាច់ជាឈាមរបស់ខ្លួននោះផង" និយាយហើយនាងក៏ចោលខ្សែភ្នែកទៅពាសពេញបរិវេណនោះ ។

"ម្នាលប្អូនស្រី" ព្រះតថាគតជាម្ចាស់ទ្រង់ត្រាស់ដោយព្រះសូរសៀងពីរោះគឹកកងលន្លោចដូចដើម **"រឿងនេះមានតែយើងពីរនាក់ប៉ុណ្ណោះដែលដឹង ថាពិតឬមិនពិត"** ព្រះអរហន្តមុនីសម្មាសម្ពុទ្ធទ្រង់ត្រាស់តែត្រឹមនេះក៏ទ្រង់គង់នៅស្ងៀម ។ ព្រះតម្រាស់ខ្លីៗ តែមានន័យជ្រាលជ្រៅនេះឯង បានបុកទំលុះពុសចំអារម្មណ៏របស់នាងយ៉ាងខ្លាំង ប្រៀបដូចជាត្រូវគេបាញ់ដោយព្រួញជ័រឆក់ដែលពោរពេញទៅដោយថ្នាំពិសដោយមិនដឹងខ្លួន នាងភ្ញាក់យ៉ាងខ្លាំង ដៃជើងនិងមាត់ញ័រទទ្រើកអស់មួយសន្ទុះ លុះប្រមូលស្មារតីបានដូចដើមវិញហើយនាងក៏តបតទៅវិញភ្លាមថា "មែន! ព្រះគោតម ក៏នៅក្នុងព្រះគន្ធកុដិដែលងងឹតបិទជិតនោះមាននរណាគេនឹងទៅរួមដឹងរួមឃើញជាមួយយើង ក្រៅពីយើងពីរនាក់ ពូកែនិយាយបានដោយមិនមានការញាប់ញ័រអ្វីបន្តិចសោះតែម្ដង មានតែយើងពីរនាក់ប៉ុណ្ណោះដែលដឹង" នាងនិយាយបណ្ដើរកម្ញើញសំពត់តន្ត្រំដីបណ្ដើរ ដោយអារម្មណ៏ក្រោធដែលចាប់ផ្ដើមឆាបឆេះឡើងបន្តិចម្ដងៗ ។

**"ប្រាកដហើយប្អូនស្រី តថាគតធានាអះអាងនូវពាក្យនោះ"**

ម្នាលអាវុសោ! មិនដឹងថាដោយហេតុចៃដន្យឬក៏ព្រោះតែវិបាកនៃកម្មដ៏ចាស់ក្លារបស់នាង យ៉ាងណានោះ វាជារឿងដែលស្មានមិនត្រូវ ពេលដែលនាងស្រែកជេរប្រទេចព្រះសាស្ដាបណ្ដើរលោត

តន្ត្រីដីបណ្តើរ ខ្សែដែលនាងចងកំណាត់ឈើរុំដោយសំពត់ចាស់ស្តើងៗ ក៏ដាច់ធ្លាក់ចុះមក រឿងរ៉ាវទាំងអស់ក៏ប្រាកដជាក់ស្តែង ការមានផ្ទៃពោះរបស់នាងក៏ប្រាកដឡើងប្រត្យក្សចំពោះភ្នែកមហាជនច្បាស់ជាងពាក្យរៀបរាប់ណាៗទាំងអស់ ។ នាងបានសំរាលកូនគឺកំណាត់ឈើនិងសំពត់ចាស់ ចំកណ្តាលចំណោមមហាជននោះឯង មនុស្សទាំងឡាយមានការភ្ញាក់ផ្អើលស្រឡាំងកាំង តែក៏មានលក្ខណៈនៃសេចក្តីរីករាយយ៉ាងជាក់ច្បាស់ ។ នាងចិញ្ចមាណវិកាភិតភ័យយ៉ាងខ្លាំង ទឹកមុខស្លេកស្លាំងបីដូចជាមនុស្សស្លាប់ ។ ប្រជាជនបានឃើញហេតុការណ៍ជាក់ច្បាស់នឹងភ្នែកដូច្នោះម្នាក់ៗបានធូរស្រាលក្នុងចិត្តដែលព្រះតថាគតជាអ្នកបរិសុទ្ធិចាកផុតមន្ទិលទាំងពួង ហើយអារម្មណ៍ថ្មីក៏ឆាបឆេះឡើងក្នុងដួងចិត្តស្ទើរគ្រប់ដួង នោះគឺការខឹងសម្បានិងស្អប់ខ្ពើមនាងចិញ្ចាមាណវិកា ពួកគេនាំគ្នាជេរប្រទេចផ្តាសារនាងអោយជួបប្រទះតែនឹងសេចក្តីទុក្ខសមតាមកម្មដ៏លាមកដែលនាងបានធ្វើ អ្នកខ្លះកាន់កំណាត់ឈើនិងដុំថ្មដេញគប់ ដេញវាយអោយនាងចេញអោយផុតពីវត្តជេតពន ក្រោយមកនាងក៏ក្ស័យជីវិត ដោយអាការៈដ៏គួរអោយសង្វេគ ។

អនិច្ចា! រូបសម្ផស្សដ៏ស្រស់ត្រកាលប្រៀបបាននឹងទេពអប្សរ តែរុំស្រោបទៅដោយចិត្តដ៏ខ្មៅកខ្វក់ រមែងធ្វើអោយម្ចាស់រូបប្រើជាឧបករណ៍សំរាប់ប្រហារខ្លួនឯងដោយគ្មាននរណាអាចជួយបាន ។ លាភសក្ការៈរបស់ពួកអន្យតិរ្ថិយក៏សាបសូន្យ ហើយបែរជាកើតឡើងចំពោះព្រះទសពលជាម្ចាស់កាន់តែច្រើនឡើង ។ថ្ងៃក្រោយមកភិក្ខុសង្ឃបានប្រជុំគ្នា នៅក្នុងធម្មសភាសាលានិយាយពីរឿងនាងចិញ្ចមាណវិកា ព្រះតថាគតស្តេចយាងមកទ្រង់ជ្រាបហើយ ទ្រង់ត្រាស់ថា *"ភិក្ខុទាំងឡាយ! បុគ្គលកាលមិនទាន់ពិចារណាឬមិនទាន់ឃើញទោសរបស់អ្នកដទៃដោយជាក់ច្បាស់ មិនគួរដាក់ទោសទណ្ឌអ្នកណាឡើយ ម្យ៉ាងទៀតអ្នកដែលបោះបង់ពាក្យសច្ចៈ ចូលចិត្តនិយាយតែពាក្យមុសា មិនខ្វល់ខ្វាយក្នុងរឿងបរលោក ឈ្មោះថាមិនធ្វើបាប នោះគឺមិនមាន ( ឈ្មោះថាជាអ្នកធ្វើនូវអំពើបាប)"*

ម្នាលលោកដ៏មានអាយុ! ហេតុការណ៍នេះជារឿងធំបំផុតដែលកើតឡើងចំពោះព្រះអង្គ ជារឿងដែលដឹងសាយសុះទូទៅក្នុងជុំនុំជនគ្រប់ស្រទាប់វណ្ណៈ ចាស់ទុំព្យាយាមប្រៀនប្រដៅកូនចៅថា កុំយកតម្រាប់តាមនាងចិញ្ចា ហើយចងជាពាក្យភាសិតថា "កុំគប់លាមកដាក់មេឃ"

ម្នាលអ្នកស្វែងរកសន្តិវរបទ! ព្រះតថាគតធ្លាប់ទ្រង់បានត្រាស់ជានិច្ចមកហើយថាៈ

*"មនុស្សដែលកើតមកហើយ គ្រប់គ្នាមានអាវុធជាប់មាត់មកជាមួយផងសំរាប់អោយបុគ្គលពាលដែលចូលចិត្តនិយាយអាក្រក់ ទុកគ្រាន់កាប់ចាក់សំឡេះខ្លួនឯង ម្យ៉ាងទៀត អ្នកណាតិះដៀលបុគ្គលដែលគួរសរសើរ ឬ សរសើរបុគ្គលដែលគួរតិះដៀល អ្នកនោះឈ្មោះថាស្វែងរកទោសដាក់ខ្លួនព្រោះមាត់របស់ខ្លួនឯង គេរមែងរកសេចក្តីស្ងប់មិនបានព្រោះទោសនោះៗ ។ ការចាញ់ល្បែងភ្នាល់អស់ទ្រព្យរលីងពីខ្លួនក៏នៅចាត់ទុកថាមានទោសតិចបើប្រៀបធៀបទៅនឹងការធ្វើចិត្តអោយគិតប្រទូសរ៉ាយ ចំពោះព្រះសុគត ការពោលមួលបង្កាច់ព្រះពុទ្ធជាម្ចាស់នេះឯងមានទោសធ្ងន់ធ្ងរណាស់"*

*"អ្នកប្រទូសរ៉ាយចំពោះបុគ្គលអ្នកមិនប្រទូសរ៉ាយ ជាអ្នកបរិសុទ្ធិ មិនមានកិលេស រមែងបានទទួលបាបដោយខ្លួនឯង ដូចជាមនុស្សបាចធូលីឡើងលើអាកាស ឬបាចធូលីបញ្ច្រាសខ្យល់"*

*"បុគ្គលលោភលន់ហួសប្រមាណ គ្មានសទ្ធា កំណាញ់ស្វិត មិនដែលរវល់នឹងពាក្យអង្វរកររបស់អ្នកជួបប្រទះសេចក្តីទុក្ខលំបាក ចូលចិត្តនិយាយពាក្យចាក់ដោត រមែងជាអ្នកចូលចិត្តជេរប្រទេចអ្នកដទៃជានិច្ច"*

ហេតុការណ៍កាលនោះជាមេរៀនដ៏គ្រប់គ្រាន់មួយ សំរាប់អ្នកដែលមានបំណងអាក្រក់ចំពោះព្រះសម្មាសម្ពុទ្ធនិងព្រះពុទ្ធសាសនា រឿងមួលបង្កាច់ទាំងឡាយក៏ស្ងប់ស្ងាត់ទៅអស់រយៈពេលជាច្រើនឆ្នាំ ។

ជាតិមនុស្សក្នុងលោកិយ រស់លើដីជ្រកមេឃា
មានឈាមពណ៌ដូចគ្នា មានជរាឈឺមរណា ។
បានកើតជាមនុស្សហើយ ចុះម្តេចឡើយមិនឧស្សាហ៍
សាងល្អអបជីវ៉ា អោយជីវិតបានសុខសាន្ត ។
ម្តេចប្រឹងខំប្រជែង អួតជំទែងដណ្តើមឋាន
ប្រកួតរឿងសាមាន្យ យកមុខមាត់ខុសផ្លូវគាប់ ។
កិត្តិយសឈ្មោះនាមា ចង់ទាមទារយកមកទ្រាប់
តែធ្វើរឿងអភ័ព្វ ខុសតម្រាព្រះសំដែង ។
ចង់បានឋានកិត្តិយស ចង់ខ្ពង់ខ្ពស់ធ្វើឫកខែង

មិនគិតពាក្យចាស់ថ្លែង ថាចេះឯងក្រែងចេះគេ ។
ជីវិតនេះខ្លីណាស់ ប៉ែតសិបចាស់ស្លាប់មិនរេ
ជួបគ្នាមិនយូរទេ ត្រូវព្រាត់ប្រាស់និរាសប្រាណ ។
ហេតុនេះពេលជួបគ្នា គួរខំវៀរចិត្តសាមាន្យ
កុំសាងរឿងរឱស្ថាន នាំរំខានប្រាសសាន្តសុខ ។
គួរខំចាប់ដៃគ្នា ស្រាយវេរារឿងស្មាញស្មុគ
សាងមិត្តមិនរើសមុខ មិនរើសអើងឆ្មើងអប្រិយ ។
ឆ្មៃឆ្មើងតំកើងខ្លួន ឫកហំហួនបានការអ្វី
បានត្រឹមតែលោកិយ សើចចំអកឫកទុរយស ។
អំនួតអួតក្អេងក្អាង មិនមែនសាងកេរ្តិ៍ឈ្មោះ
បើចង់បានកិត្តិយស ត្រូវរៀនលះរៀនសាងល្អ ។
រៀនមានចិត្តមេត្តា ដួងចិន្តាអោយស្មោះសរ
មានយសព្រោះសាងល្អ មិនមែនព្រោះល្បិចកិច្ចកល ។
ហៃ! អស់សប្បុរសអើយ កុំកន្តើយឆាប់ខ្វាយខ្វល់
ជំរុះចិត្តអកុសល សាងក្តីសុខត្រាប់ធម្មា ។
កុំខំធ្វើក្រអឺត កុំជំទើតចងកម្មពៀរ
ជាតិមនុស្សដូចតែគ្នា ចេះស្រលាញ់រួសរាក់ទាក់ ។
សង្គមនឹងបានស្ងប់ ផុតក្តីស្អប់ខ្ពើមអបលក្ខណ៏
ញញឹមដោយស្មោះស្ម័គ្រ ចាប់ដៃគ្នាស្ទួយពុទ្ធសាសន៏ ។

២២ សីហា ២០០៦